**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះ**

**ក្រុមលទ្ធកម្ម**

លេខ : ០០៣៧.សក.ក្រច.កល

## សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃការងារជួសជុលរបង និងអគាររដ្ឋបាល របស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះ សម្រាប់ឆ្នាំ ២០១៨

មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារជួសជុលរបង និងអគាររដ្ឋបាល របស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះ សម្រាប់ឆ្នាំ ២០១៨។

មន្ទីរសាធារណការ និងដឹកជញ្ជូន បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។

ឯកសារដេញថ្លៃ មានដាក់លក់នៅក្រុមលទ្ធកម្ម មន្ទីរសាធារណការ និងដឹកជញ្ជូន ដែលមានអាសយដ្ឋាន ភូមិក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ចាប់ពីថ្ងៃទី ២៥... ខែមិថុនា..ឆ្នាំ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០១១ ៦៨២ ៥៨៨) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្ម មន្ទីរសាធារណការ និងដឹកជញ្ជូន យ៉ាងយូរបំផុត ត្រឹមថ្ងៃទី ២៥.. ខែកក្កដា..ឆ្នាំ២០១៨ វេលាម៉ោង ១០:៣០.. ។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅមន្ទីរសាធារណការ និងដឹកជញ្ជូន តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១០:៣០ ថ្ងៃទី ២៥.. ខែកក្កដា.. ឆ្នាំ២០១៨ ។

បានពិនិត្យត្រឹមត្រូវ

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្ម មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះ ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃច័ន្ទ ១២កើត ខែជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅក្រចេះ, ថ្ងៃទី ២៥.. ខែមិថុនា ឆ្នាំ២០១៨

**ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន**

**និងជាប្រធានក្រុមលទ្ធកម្ម**

ស្រេង ស្រស់

ចម្លងជូន ÷

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

ឯកសារ "កាលប្បវត្តិ"